**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៨៤៩ ព.ណ.ជ.ព

ថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

យោងតាមលិខិតលេខ ៦៩៥៤ កបទ.សអ.អប១ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសេចក្តីប្រកាសព័ត៌មាន ស្តីពីលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរសេដ្ឋកិច្ច និងអភិវឌ្ឍន៍ជាតិហ្វីលីពីនលើកទី១៧ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៤។

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ជាផលិតករ ឬអ្នកនាំចេញទាំងអស់ដែលនាំចេញផលិតផលទៅកាន់ទីផ្សារហ្វីលីពីនឱ្យបានជ្រាបថាលទ្ធផលនៃកិច្ចប្រជុំខាងលើ បានសម្រេចកាត់បន្ថយអត្រាពន្ធគយលើមុខទំនិញ សារធាតុគីមីមួយចំនួន និងធ្យូងថ្ម(Coal Briquettes) និងបានឯកភាពបន្តរក្សាអត្រាពន្ធគយ ដែលបានកាត់បន្ថយពីមុនលើមុខទំនិញ ពោត សាច់ជ្រូក និងសាច់សុទ្ធ រហូតដល់ ឆ្នាំ២០២៨។

ជាពិសេសនាំចូលអង្ករពី ៣៥% ត្រូវបានកាត់បន្ថយពន្ធមកនៅត្រឹម ១៥% រហូតដល់ឆ្នាំ២០២៨ សម្រាប់អត្រាក្នុងកូតា និងក្រៅកូតា (In-quota and out-quota rates) ដែលស្ថិតនៅក្រោមកម្មវិធីពន្ធគ្រប់ជ្រុងជ្រោយថ្មី (The New Comprehensive Tariff Program) ដោយក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរសេដ្ឋកិច្ច និងអភិវឌ្ឍន៍ជាតិហ្វីលីពីន លើកទី១៧។

ចំពោះព័ត៌មានលម្អិត សូមទំនាក់ទំនងមកអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈទូរសព្ទលេខ៖ ១២៦៦ / ០១២ ៨៣៣ ៣៩៧ / ០១១ ៧៥៧ ១៦៥ ឬតាមរយៈអ៊ីមែល៖ dexim@moc.gov.kh។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ជាផលិតករ ឬអ្នកនាំចេញទាំងអស់ ជ្រាបជាព័ត៌មាន។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469